**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

នាយកដ្ឋានព័ត៌មាន

# សេចក្តីជូនព័ត៌មាន
# ស្តីពីលទ្ធផលនៃកិច្ចប្រជុំកំពូលពិសេសអាស៊ាន-អូស្ត្រាលី
# ថ្ងៃទី ១៦ -១៨ ខែមីនា ឆ្នាំ២០១៨
# ទីក្រុងស៊ីដនី អូស្ត្រាលី

================

តបតាមការអញ្ជើញរបស់ **ឯកឧត្តម ម៉ាល់កុម ធឺនប៊ុល** (Malcolm Turnbull) នាយករដ្ឋមន្ត្រីអូស្ត្រាលី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់អញ្ជើញចូលរួមកិច្ចប្រជុំកំពូលពិសេសអាស៊ាន-អូស្ត្រាលី ដែលបានប្រព្រឹត្តទៅពីថ្ងៃទី ១៦ ដល់ថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១៨ នៅទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី។

កិច្ចប្រជុំកំពូលពិសេសក្រោមប្រធានបទ «**ការលើកកម្ពស់សន្តិសុខ និងវិបុលភាពក្នុងតំបន់**» ដែលត្រូវបានរៀបចំឡើងជាលើកទីមួយនៅអូស្ត្រាលី បន្ទាប់ពីរយៈពេលជាង៤ទសវត្សនៃទំនាក់ទំនង បានឆ្លុះបញ្ចាំងពីការទទួលស្គាល់ទំនាក់ទំនងយុទ្ធសាស្ត្ររបស់អូស្ត្រាលីជាមួយអាស៊ាន និងបានកំណត់នូវសករាជថ្មីនៃទំនាក់ទំនងដៃគូសន្ទនារវាងអាស៊ាន-អូស្ត្រាលី។ នៅមុនកិច្ចប្រជុំកំពូលពិសេសនេះ ប្រទេសអូស្ត្រាលីបានរៀបចំកិច្ចប្រជុំសំខាន់ៗចំនួន២ គឺកិច្ចប្រជុំកំពូលស្តីពីធុរកិច្ច និងសន្និសីទស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម ជាមួយគោលបំណងជានាឱ្យបាននូវឱកាសប្រសើរជាងមុនសម្រាប់វិស័យធុរកិច្ច និងលើកឡើងអំពីការប្រឈមផ្នែកសន្តិសុខរួម។

កិច្ចប្រជុំកំពូលបានទទួលស្គាល់ពីតួនាទីស្នូលរបស់អាស៊ាន នៅក្នុងដំណើរវិវត្តន៍និម្មាបនកម្មតំបន់ក្នុងការថែរក្សាសន្តិភាព ស្ថិរភាព និងកំណើនប្រកបដោយបរិយាប័ន្ន ការរួមចំណែករបស់អាស៊ាននៅក្នុងរយៈកាល៥០ឆ្នាំកន្លងទៅ ដើម្បីសន្តិភាព និងវិបុលភាពតំបន់ ព្រមទាំងបានកោតសរសើរចំពោះការរួមចំណែករបស់អូស្ត្រាលីដល់ការកសាងសហគមន៍អាស៊ានផងដែរ។ កិច្ចប្រជុំកំពូលនេះបានបញ្ជាក់ជាថ្មីនូវសារៈសំខាន់ដ៏ចាំបាច់នៃការគោរពគ្នាទៅវិញទៅមកសំរាប់គោលការណ៍អធិបតេយ្យភាព បូរណភាពដែនដី សមភាព និងការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង ដូចដែលមានចែងនៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ធម្មនុញ្ញអាស៊ាន និងសន្ធិសញ្ញាមិត្តភាពនិងកិច្ចសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍។

នៅក្នុងកិច្ចប្រជុំកំពូល ថ្នាក់ដឹកនាំទាំងអស់បានប្តេជ្ញាចិត្តបង្កើនការឆ្លើយតបចំពោះបញ្ហាប្រឈមក្នុងតំបន់និងសាកលលោក ដែលរួមមានបញ្ហាឧបទ្វីបកូរ៉េ ភេរវកម្មនិងជ្រុលនិយមហឹង្សា និងសមុទ្រចិន



អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

ខាងត្បូង។ ថ្នាក់ដឹកនាំ បានឯកភាពពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកសមុទ្រ កិច្ចការព័ត៌មានវិទ្យា (cyber affairs) ការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសឧក្រិដ្ឋកម្មឆ្លងដែន និងការដោះស្រាយចំពោះការគំរាមកំហែងថ្មីៗផ្នែកសុខភាពក្នុងតំបន់។ ថ្នាក់ដឹកនាំក៏បានឯកភាពក្នុងការបង្កើនទំនាក់ទំនងផ្នែកពាណិជ្ជកម្ម ការវិនិយោគនិងធុរកិច្ច ព្រមទាំងជម្រុញទៅមុខនូវគំនិតផ្តួចផ្តើមថ្មីនៃទីក្រុងឆ្លាត (smart cities) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងកិច្ចសហប្រតិបត្តិការគោលនយោបាយសេដ្ឋកិច្ច។ អូស្ត្រាលីបានប្រកាសសន្យាផ្តល់ប្រាក់៨០លានដុល្លារអូស្ត្រាលី សម្រាប់បន្តកិច្ចសហប្រតិបត្តិការជាមួយអាស៊ាន ដើម្បីប្រឆាំងនឹងការជួញដូរមនុស្ស។ អូស្ត្រាលីក៏បានប្រកាសផងដែរថា ដើម្បីពង្រឹងការផ្លាស់ប្តូរការសិក្សាទៅវិញទៅមករវាងអាស៊ាន-អូស្ត្រាលី អូស្ត្រាលីនឹងផ្តល់អាហារូបករណ៍ "Australia Awards ASEAN Scholarship" ចំនួន៥០កន្លែង ដល់អ្នកដឹកនាំជំនាន់ក្រោយ មកពីបណ្តាប្រទេសអាស៊ាន សម្រាប់បន្តការសិក្សាថ្នាក់ក្រោយឧត្តមនៅប្រទេសអូស្ត្រាលី។

ថ្នាក់ដឹកនាំបានអនុម័ត "**សេចក្តីប្រកាសរួមកិច្ចប្រជុំកំពូលពិសេសអាស៊ាន-អូស្ត្រាលី៖ សេចក្តីប្រកាសទីក្រុងស៊ីដនី**" (ដូចមានជូនភ្ជាប់) ដែលជាផែនទីបង្ហាញផ្លូវសម្រាប់ពង្រឹងថែមទៀត និងជម្រុញទំនាក់ទំនងភាពជាដៃគូអាស៊ាន-អូស្ត្រាលីសម្រាប់ទសវត្សរ៍ខាងមុខ។ ថ្នាក់ដឹកនាំក៏បានអញ្ជើញជាសក្ខីភាពក្នុងពិធីចុះហត្ថលេខាលើ "អនុស្សរណៈនៃការយោគយល់គ្នារវាងអាស៊ាន និងអូស្ត្រាលី ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងភេរវកម្មអន្តរជាតិ"។

នៅក្នុងកិច្ចប្រជុំកំពូលនេះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានថ្លែងបទអន្តរាគមន៍ចំនួនបី ដែលក្នុងនោះ សម្តេចតេជោបានគូសបញ្ជាក់ថា៖

- នៅក្នុងបរិបទនៃការផ្លាស់ប្តូរយ៉ាងលឿននៃនិម្មាបនកម្មតំបន់និងភូមិសាស្ត្រនយោបាយ ក៏ដូចជាការរីកចម្រើននៃទំនាក់ទំនងអាស្រ័យគ្នាទៅវិញទៅមករវាងតំបន់អាស៊ាននិងអូស្ត្រាលី សន្តិភាព សន្តិសុខ និងស្ថិរភាព គឺចំណុចស្នូលសម្រាប់ទំនាក់ទំនងអាស៊ាន-អូស្ត្រាលី និងជាមូលដ្ឋានគ្រឹះនៃការរីកចម្រើន និងវិបុលភាព នៅក្នុងតំបន់ទាំងមូល។
- មានភាពចាំបាច់ដែលត្រូវជំរុញថែមទៀត នូវកិច្ចសហប្រតិបត្តិការក្នុងវិស័យអប់រំ ដោយការផ្តល់អាហារូបករណ៍សម្រាប់និស្សិតអាស៊ាន តាមរយៈផែនការកូឡំបូថ្មីរបស់អូស្ត្រាលី។
- វាជាកិច្ចការបន្ទាន់ ក្នុងការសម្រេចបញ្ចប់កិច្ចចរចាភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ (RCEP) នៅក្នុងឆ្នាំ២០១៨ នេះ។
- **សម្តេចតេជោ**ក៏បានជម្រុញភាគីអូស្ត្រាលី បន្តគាំទ្រតួនាទីស្នូលរបស់អាស៊ានក្នុងនិម្មាបនកម្មតំបន់ ជាពិសេសតាមរយៈយន្តការកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធិភាពខ្ពស់ទៅនឹងបញ្ហាប្រឈមសន្តិសុខមិនប្រពៃណីនានា ដូចជាបញ្ហាភេរវកម្ម គ្រោះមហន្តរាយធម្មជាតិ ការប្រែប្រួលអាកាសធាតុ អន្តោប្រវេសន៍អន្តរជាតិ និងជំងឺរាតត្បាតជាដើម ដើម្បីធានាឲ្យបាននូវសុខដុមរមនាជូនប្រជាជនក្នុងតំបន់អាស៊ីបូព៌ា។

ក្នុងអំឡុងពេលស្នាក់នៅអូស្ត្រាលី **សម្តេចតេជោ** និងថ្នាក់ដឹកនាំអាស៊ានផ្សេងទៀត បានចូលរួមពិសារអាហារថ្ងៃត្រង់ រៀបចំដោយឯកឧត្តម ភីធ័រ ខូសហ្គ្រូវ (Peter Cosgrove) អគ្គទេសាភិបាលអូស្ត្រាលី។

នៅក្នុងឱកាសស្នាក់នៅអូស្ត្រាលីនេះដែរ **សម្តេចតេជោ ហ៊ុន សែន** ក៏បានជួបប្រជុំទ្វេភាគីជាមួយ ឯកឧត្តម **ម៉ាល់កុម ធើនប៊ុល** នាយករដ្ឋមន្ត្រីអូស្ត្រាលី។ នៅក្នុងកិច្ចប្រជុំ **សម្តេចតេជោ** បានជម្រាបសមភាគីអូស្ត្រាលី ពីការវិវត្តនៃសភាពការណ៍នយោបាយថ្មីៗក្នុងប្រទេសកម្ពុជា ស្ថានភាពសេដ្ឋកិច្ចដ៏ល្អប្រសើរ និងកិច្ចខិតខំប្រឹងប្រែងរក្សាបាននូវសន្តិភាព សន្តិសុខ និងស្ថិរភាព។

ចំពោះកិច្ចសហប្រតិបត្តិការទ្វេភាគី ថ្នាក់ដឹកនាំទាំងពីរ បានឯកភាពគ្នាក្នុងការពង្រឹងបន្ថែមនូវកិច្ចសហប្រតិបត្តិការ ជាពិសេសលើការអភិវឌ្ឍធនធានមនុស្ស ជំនួយក្នុងការដោះមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅកម្ពុជា និងមជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន។ ថ្នាក់ដឹកនាំក៏បានអះអាងពីចំណងទាក់ទងរវាងប្រទេសទាំងពីរ ដោយពង្រឹងថែមទៀតការអនុវត្តអនុស្សារណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអូស្ត្រាលីស្តីពីការទទួលជនភៀសខ្លួនមកតាំងទីលំនៅនៅកម្ពុជា ដែលបានចុះហត្ថលេខាកាលពីឆ្នាំ២០១៤ នៅទីក្រុងភ្នំពេញ។ ថ្នាក់ដឹកនាំ នឹងជម្រុញឲ្យមានការបង្កើតកិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ក្នុងវិស័យនយោបាយ សន្តិសុខ សេដ្ឋកិច្ច និងវប្បធម៌ តាមបញ្ញត្តិនៃអនុស្សារណៈនៃការយោគយល់គ្នា ស្តីពីការបង្កើតកិច្ចពិគ្រោះយោបល់ថ្នាក់ឧត្តមមន្ត្រីរវាងក្រសួងការបរទេសកម្ពុជានិងអូស្ត្រាលី ដែលបានចុះហត្ថលេខាកាលពីខែតុលា ឆ្នាំ២០១៧។ នាយករដ្ឋមន្ត្រីអូស្ត្រាលី Turnbull បានសន្យាផ្តល់ជំនួយប្រមាណ៨៧លានដុល្លារអូស្ត្រាលី សម្រាប់អភិវឌ្ឍន៍នៅកម្ពុជា សម្រាប់ឆ្នាំ២០១៨ និងពង្រឹងបន្ថែមទៀតនូវទំនាក់ទំនងទ្វេភាគី ដោយការលើកទឹកចិត្តអ្នកវិនិយោគកាន់តែច្រើនមកកម្ពុជា។ បន្ថែមពីនេះ ឯកឧត្តមក៏បានថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលកម្ពុជាដែលបានគាំទ្រកម្មវិធីកូឡុំបូថ្មី។ ជាមួយគ្នានោះ **សម្តេចតេជោ** ក៏បានអញ្ជើញឯកឧត្តមនាយករដ្ឋមន្ត្រី Turnbull មកបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជា។

នាអំឡុងពេលស្នាក់នៅប្រទេសអូស្ត្រាលី **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានជួបសំណេះសំណាល និងពិសារបាយសាមគ្គី នៅរាត្រីថ្ងៃទី ១៦ និង១៧ ខែមីនា ជាមួយជនរួមជាតិខ្មែរជាង១៥០០នាក់ ដែលរស់នៅប្រទេសអូស្ត្រាលី និងនូវែលហ្សេឡង់។ ក្នុងឱកាសនោះ **សម្តេចតេជោ**បានលើកឡើងពីស្ថានការណ៍នយោបាយ ភាពប្រសើរឡើងនៃសេដ្ឋកិច្ចកម្ពុជា កំណើនភ្ញៀវទេសចរណ៍មកកម្ពុជា ជីវភាពរស់នៅកាន់តែប្រសើរឡើង វិធានការពង្រឹងនីតិរដ្ឋ និងជាពិសេសកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការនាំមកនូវសន្តិភាព ការបង្រួបបង្រួមជាតិ ស្ថិរភាពនយោបាយ និងការអភិវឌ្ឍលើគ្រប់វិស័យ។

សម្តេចតេជោក៏បានទទួលការចូលជួបសម្តែងការគួរសមរបស់ **លោក ជេរ៉េមី ចនសុន** ប្រធានសភាពាណិជ្ជកម្ម និងឧស្សាហកម្មអូស្ត្រាលីផងដែរ។ ការពិភាក្សាបានផ្តោតជាសំខាន់លើទំនាក់ទំនងសេដ្ឋកិច្ចរវាងប្រទេសទាំងពីរ។

ថ្ងៃអង្គារ ៤កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមីនា ឆ្នាំ២០១៨